ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨

## អគ្គនាយកដ្ឋានគោលនយោបាយ
## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែតុលា ឆ្នាំ២០១៨

# មាតិកា


I. សេចក្តីអធិប្បាយសង្ខេប ....................................................... ១

II. ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ....................................................... ៥

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ ....................................................... ៥

២. សូចនាករតាមវិស័យ ....................................................... ៧

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ....................................................... ៧

២.៣. អត្រាប្តូរប្រាក់ ....................................................... ៨

២.៤. ហិរញ្ញវត្ថុសាធារណៈ ....................................................... ៩

២.៥. ឥណទាន និងរូបិយវត្ថុ ....................................................... ១៣

២.៦. វិស័យពាណិជ្ជកម្ម ....................................................... ១៤

២.៧. ការវិនិយោគឯកជន ....................................................... ១៧

២.៨. វិស័យទេសចរណ៍ ....................................................... ១៨

២.៩. វិស័យសំណង់ ....................................................... ១៩

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ ....................................................... ២០

III. ឧបសម្ព័ន្ធ ....................................................... ២៣

# សេចក្តីអធិប្បាយសង្ខេប

ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ បានបន្តរឹងមាំ និងធន់នឹងវិបត្តិជាងបណ្តាត្រីមាសក្នុងឆ្នាំមុនៗ។ អត្រាអតិផរណានិងប្តូរប្រាក់ ប្រែប្រួលក្នុងរង្វង់ដែលអាចគ្រប់គ្រងបាន។ ទំហំពាណិជ្ជកម្មនាំចេញផ្នែកផលិតកាត់ដេរនិងស្បែកជើង មានសន្ទុះកំណើនខ្លាំង ខណៈទំហំពាណិជ្ជកម្មនាំចូលសម្រាប់បម្រើតម្រូវការក្នុងស្រុកទាំងផ្នែកលក់ដុំ-រាយ និងនាំចេញវិញ មានភាពប្រសើរជាងការរំពឹងទុក។ ស្ថានភាពចំណូលនិងចំណាយចរន្ត បានបន្តភាពប្រសើរឡើង និងរក្សាបានលំនឹងអតិរេកចរន្ត។ ទន្ទឹមនេះ សកម្មភាពវិនិយោគឯកជន, សំណង់ និងទេសចរណ៍រក្សាបានគួរលេខល្អ។

**កសិកម្ម** [1]

**សកម្មភាពកសិកម្មត្រឹមត្រីមាសទី៣ ឆ្នាំ២០១៨ មានភាពល្អប្រសើរ ស្របគ្នានឹងការបណ្តាក់ទុនវិនិយោគបន្ថែមរបស់ឯកជនលើវិស័យកសិកម្ម ក្នុងឆ្នាំ២០១៧។** ជាក់ស្តែង ផ្ទៃដីដាំដុះស្រូវព្រមទាំងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម មានកំណើនក្នុងអត្រា ៤,៥% និង ៦,៣% លើផ្ទៃដីសរុបប្រមាណ ៣,៧ លានហិកតា ច្រើនជាងត្រីមាសដូចគ្នាឆ្នាំ២០១៧ ប្រមាណជិត ២សែនហិកតា។ ទន្ទឹមនឹងការជំរុញផលិតកម្មស្រូវ និងការអភិវឌ្ឍវិស័យជលផល កម្ពុជាបានផលិតស្រូវក្នុងបរិមាណផល ១,៧ លានតោន និងអាចយកផលពីវិស័យជលផល បានក្នុងរង្វង់ ៥៦៨ ពាន់តោន មានកំណើនក្នុងអត្រា ២៣,៣% និង ៧,៦% ធៀបឆ្នាំមុន។

យោងតាមស្ថិតិអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ការនាំចេញផលិតផលកសិកម្ម **ត្រឹមត្រីមាសទី៣ នេះ** មានកំណើនខ្លាំងក្នុងអត្រា ៣៥,២% ក្នុងនោះការនាំចេញអង្ករ សម្រេចបាន ៣៩៦ ពាន់តោន, ស្ករ ២៩៦ ពាន់តោន, កៅស៊ូ ១០៨ ពាន់តោន និងផលិតផលកសិកម្មផ្សេងៗសម្រេចបាន ២៨២ ពាន់តោន។

**ទេសចរណ៍** [2]

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨នេះ កម្ពុជារំពឹងថាទទួលបានអ្នកដំណើរប្រមាណជា ១,៤ លាននាក់ ក្នុងអត្រាកំណើន ១១,៤% (*)ក្នុងនោះ ចំនួនភ្ញៀវចូលតាមព្រលានយន្តហោះអន្តរជាតិ មានកំណើនខ្ពស់ក្នុងអត្រា ២៤,៩%។ សម្រាប់ទីផ្សារទេសចរណ៍ ភ្ញៀវពីតំបន់អាស៊ីប៉ាស៊ីហ្វិកដែលមានចំណែក ៨២,៣% នៃទីផ្សារសរុប មានកំណើន ១៣,៩% ស្របគ្នានឹងកំណើន ៤,៨% នៃភ្ញៀវពីតំបន់អឺរ៉ុប។ ប៉ុន្តែភ្ញៀវពីអាមេរិក បានធ្លាក់ចុះ ៦,៨%។

[1] ប្រភពទិន្នន័យៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[2] ប្រភពទិន្នន័យៈ ក្រសួងទេសចរណ៍

(*) ធ្វើចំណោលទិន្នន័យទេសចរណ៍ខែកញ្ញា សម្រាប់ប៉ាន់ស្មានចំនួនភ្ញៀវក្នុងត្រីមាសទី៣។ ទិន្នន័យនេះ នឹងកែសម្រួលឡើងវិញក្នុងត្រីមាសទី៤

**សំណង់** [3]

សកម្មភាពទីផ្សារវិស័យសំណង់ បានបន្តមានវឌ្ឍនភាពកាន់តែរឹងមាំ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨ ដែលត្រូវបានទ្រទ្រង់ដោយកំណើនខ្ពស់នៃក្រឡាផ្ទៃសំណង់ប្រភេទពាណិជ្ជកម្ម, ទេសចរណ៍, សាធារណៈ និងលំនៅដ្ឋាន ដែលជាប្រភេទសំណង់មានតម្លៃសមរម្យនិងមធ្យម ដែលជួយប៉ះប៉ូវដល់កំណើនយឺតនៃប្រភេទសំណង់លំនៅដ្ឋានមានតម្លៃខ្ពស់។ ការផ្តល់លិខិតអនុញ្ញាតសាងសង់ទូទាំងប្រទេសមាន ៨៨៩ គម្រោង (ធ្លាក់ចុះ ១០,១%) ប្រហាក់ប្រហែលនឹង ២ ៦៦៧ លានដុល្លារ (មានកំណើន ០៤ ដង) លើក្រឡាផ្ទៃសំណង់សរុប ៥,៦ លាន ម៉ែត្រការ៉េ (មានកំណើន ០៣ ដង)។ ទោះបីជាគម្រោងសាងសង់មានការថមថយបន្តិចក្តី តាមរយៈកំណើនផ្ទៃក្រឡាសំណង់និងទុនវិនិយោគខាងលើ បានឆ្លុះបញ្ចាំងថា វិស័យសំណង់នៅតែរឹងមាំដដែល។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ** [4]

យោងតាមទិន្នន័យពីអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ នេះ ការប្រមូលចំណូលចរន្តសរុបនៅរដ្ឋបាលថ្នាក់ជាតិអនុវត្តបានចំនួន ៤ ៦២៥ ប៊ីលានរៀល ក្នុងនោះចំណូលពន្ធគយ អនុវត្តបាន ៥១,៧% នៃចំណូលចរន្តសរុប បានកើនឡើង ៣៣,១% ក្នុងនោះពន្ធនាំចូលបានកើន ២៣,៨%។ ចំណូលពន្ធដារ អនុវត្តបាន ៤៣,២% នៃចំណូលចរន្តសរុប បានកើនឡើង ៥,៧% ក្នុងនោះ អាករលើតម្លៃបន្ថែមនិងអាករពិសេស បានកើន ១៧,៦% និង ៣០,៥%។

ចំណាយចរន្តសរុប ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ អនុវត្តបាន ៣ ៨៨៣ ប៊ីលានរៀល បានកើន ២០,៦% ក្នុងនោះចំណាយរដ្ឋបាលទូទៅ ១២,៩% ការពារនិងសន្តិសុខ ៣៣,៣% រដ្ឋបាលសង្គមកិច្ច ២៤,៧% និងរដ្ឋបាលសេដ្ឋកិច្ច ០,៤%។ ជាលទ្ធផល អតិរេកតុល្យភាពចរន្តនៃប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ មានចំនួន ៧៤២ ប៊ីលានរៀល។

**អតិផរណា និងអត្រាប្តូរប្រាក់** [5]

អតិផរណាក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ ស្ថិតនៅក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ពោលគឺជាមធ្យមក្នុងអត្រា ២,៦% ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៧ ដោយសារកំណើនចំណាយទាបនៃក្រុមអាហារ-ភេសជ្ជៈមិនមានជាតិស្រវឹង ២,៣% ការដឹកជញ្ជូន ៣,៦% និងផ្ទះសំបែង ១,១%។ ក្នុងរយៈពេលដូចគ្នានេះ អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ពោលគឺជាមធ្យម ៤ ០៧៣ រៀល/ ដុល្លារអាមេរិក មានការប្រែប្រួលត្រឹម -០,១៦% ប៉ុណ្ណោះ។

---

3 ប្រភពទិន្នន័យៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

4 ទិន្នន័យបណ្តោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ

5 ប្រភពទិន្នន័យៈ វិទ្យាស្ថានជាតិស្ថិតិ/ ក្រសួងផែនការការ និង ធនាគារជាតិនៃកម្ពុជា

**ប្រតិបត្តិការរូបិយវត្ថុ និងឥណទាន** [6]

អត្រារូបិយវត្ថុទូទៅធៀបនឹង ផ.ស.ស (ប៉ាន់ស្មាន) មានការរីកចម្រើនយ៉ាងឆាប់រហ័ស គិតត្រឹមត្រីមាសទី៣ នេះ ពោលគឺពី ៧៧,៨% ឆ្នាំ២០១៧ ទៅ ៨៥,១% ឆ្នាំ២០១៨។ កំណើនឥណទានសរុប បានកើនពី ១៩,៥% ទៅ ២៣,២% ក្នុងនោះ ឥណទានផ្ដល់ទៅគ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ បានកើនដល់ ១៩,៣% តម្រូវការផ្ទាល់ខ្លួន ៣៤,១% និងឥណទានពី MFIs បានថមថយកំណើនមកនៅត្រឹម ២៥,៥%។ ជាការកត់សម្គាល់ ទំហំឥណទានក្នុងវិស័យ សំណង់ (*) បានបន្តកំណើនខ្ពស់ក្នុងអត្រា ៣១,២%។

**ពាណិជ្ជកម្មក្រៅប្រទេស** [7]

ការនាំចូលមុខទំនិញគ្រប់មុខ (គិតរួមទាំងការនាំចូលជាបន្ទុករដ្ឋ) នៅត្រីមាសទី៣ ឆ្នាំ២០១៨ មានទំហំ ១៧ ៨១១ ប៊ីលានរៀល ក្នុងអត្រាកំណើន ២១,៧% ធៀបនឹងឆ្នាំមុន ដោយសារកំណើនខ្ពស់លើផលិតផលនាំចូលចម្បង ដូចជា÷ បរិក្ខារសំណង់ ៦៣,៣% ប្រេងឥន្ទនៈ ៤០% ទោចក្រយានយន្ត ៣១,២% ព្រមទាំងវាយនភ័ណ្ឌនិងសម្លៀកបំពាក់ ២៤,៩%។

ចំពោះពាណិជ្ជកម្មក្រៅប្រទេស ការនាំចេញសរុបរបស់កម្ពុជា នៅត្រីមាសទី៣ ឆ្នាំ២០១៨ មានទំហំ ១៥ ៤៦៦ ប៊ីលានរៀល **ក្នុងអត្រាកំណើន ២២% ដែលជាកម្រិតមួយខ្ពស់ពុំ ធ្លាប់មាន ដោយសារកំណើនខ្ពស់នៃការនាំចេញផលិតផលកាត់ដេរនិងស្បែកជើង ២៥,២% ឧស្សាហកម្ម ១៣,៤% និងកសិកម្ម ៣២,១%។**

ផលិតផលនាំចេញទៅទីផ្សារអឺរ៉ុប (EU28) សម្រេចបាន ១ ៤៨៦ លានដុល្លារ ក្នុងអត្រាកំណើន ២២% ក្នុងនោះផលិតផលកាត់ដេរនិងស្បែកជើង ២៣,២%។ ការនាំចេញទៅទីផ្សារអាមេរិក ក៏មានស្ថានភាពប្រសើរខ្លាំង ក្នុងទឹកប្រាក់ ៩១៦ លានដុល្លារ ដោយមានកំណើនខ្ពស់ប្រមាណ ២៦,២% ក្នុងផលិតផលកាត់ដេរនិងស្បែកជើង ៣០,៣%។ ការនាំចេញរបស់កម្ពុជាទៅទីផ្សារជប៉ុន ក្នុងទឹកប្រាក់ ៣៣៨ លានដុល្លារ ក្នុងនោះ ៨១,៨% នៃការនាំចេញសរុប គឺជាផលិតផលកាត់ដេរដែលមានកំណើន ៣៥,១%។ **ឧស្សាហកម្មនាំចេញផលិតផលកាត់ដេរនិងស្បែកជើងរបស់កម្ពុជា កំពុងទទួលបានអត្ថប្រយោជន៍ជាច្រើន អំឡុងពេលសង្គ្រាមពាណិជ្ជកម្មកំពុងបន្តរវាងសហរដ្ឋអាមេរិក និងប្រទេសចិន។**

[6] ប្រភពទិន្នន័យ៖ ធនាគារជាតិនៃកម្ពុជា

(*) និយមន័យ÷ ឥណទានសំណង់, ការជួញដូរអចលនទ្រព្យ និងកម្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន ព្រមទាំងឥណទានពី MFIs សម្រាប់សំណង់

[7] ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា/ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ការវិនិយោគឯកជន** [(8)]

គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសដែលអនុម័តដោយ CDC នៅត្រីមាសទី៣ ឆ្នាំ២០១៨ មានតែ ២៩ គម្រោង លើទុនវិនិយោគ ១ ០៥៩ លានដុល្លារ ទាបជាងរយៈពេលដូចគ្នាឆ្នាំ២០១៧ ដែលមាន ៣៨ គម្រោង លើទុនវិនិយោគ ប្រមាណ ៣ ០០៥ លានដុល្លារ។ ការវិនិយោគលើវិស័យឧស្សាហកម្ម មានទុនសរុប ៤០៨ លានដុល្លារ ដែលមានកំណើនវិនិយោគប្រមាណ ៤៥,២%។ ដោយឡែកការវិនិយោគផ្នែកសេវាកម្មនិងទេសចរណ៍ បានធ្លាក់ចុះពី ២ ៥១៩ លានដុល្លារ មកនៅត្រឹម ៦១៨ លានដុល្លារ។

[8] ប្រភពទិន្នន័យៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **សូចនាករម៉ូលដ្ឋាន** | | | | |
| អតិផរណា (កំណើនប្រចាំឆ្នាំ) | % | 3.0% | 2.7% | 2.6% |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 2.4% | 3.3% | 2.4% |
| អត្រាប្តូរប្រាក់រៀល/ ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,094 | 4,080 | 4,073 |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 3,376 | 3,882 | 4,625 |
| ចំណាយចរន្ត | ប៊ីលានរៀល | (2,649) | (3,219) | (3,883) |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 730 | 637 | 742 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| កំណើនរូបិយវត្ថុទូទៅ (% នៃ ផសស) | % | 21.5% | 22.1% | 21.2% |
| អត្រារូបិយវត្ថុទូទៅ (% នៃ ផសស( | % | 70.3% | 77.8% | 85.1% |
| កំណើនឥណទាន (%) | | 22.0% | 19.5% | 23.2% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំហំពាណិជ្ជកម្មនាំចេញ | ប៊ីលានរៀល | 12,057 | 12,674 | 15,466 |
| ទំហំពាណិជ្ជកម្មនាំចូល | ប៊ីលានរៀល | (12,523) | (18,259) | (17,811) |
| តុល្យភាពពាណិជ្ជកម្ម | ប៊ីលានរៀល | (466) | (5,585) | (2,346) |
| **វិនិយោគឯកជន** | | | | |
| គម្រោង | ចំនួន | 33 | 38 | 29 |
| ទុនវិនិយោគ | លានដុល្លារ | 960 | 3,005 | 1,059 |
| បង្កើតការងារ | ពាន់នាក់ | 32,577 | 46,374 | 54,809 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | នាក់ | 1,147 | 1,250 | 1,392 |
| ក្នុងនោះ អ្នកទេសចរ | នាក់ | 1,010 | 1,093 | 1,168 |
| **វិស័យសំណង់** | | | | |
| គម្រោង | ចំនួន | 826 | 999 | 898 |
| ក្រឡាផ្ទៃ | ម២ | 1,757 | 1,859 | 5,629 |
| តម្លៃសាងសង់ | លានដុល្លារ | 727 | 692 | 2,667 |

| | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)** [9] | | | | |
| អង្ករ | ដុល្លារ/ តោន | 415 | 376 | 405 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/ បារ៉ែល | 46 | 51 | 73 |
| កៅស៊ូ | ដុល្លារ/ តោន | 1,552 | 1,837 | 1,474 |
| មាស | ដុល្លារ/ អោន | 1,470 | 1,408 | 1,318 |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

*រូបភាព 1 ÷ ស្ថានភាពសូចនាករសេដ្ឋកិច្ចសំខាន់ៗ*




ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

[9] គឺជាថ្លៃទំនិញចុងត្រីមាស

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី៣) -- ឆ្នាំ២០១៨*

| សូចនាករ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **មុខទំនិញគ្រប់មុខ** | **163.2** | **168.6** | **173.0** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 196.2 | 205.3 | 210.5 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 152.9 | 159.2 | 161.0 |
| សម្លៀកបំពាក់ និង ស្បែកជើង | 139.0 | 143.5 | 146.7 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 124.4 | 124.4 | 125.7 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 146.8 | 150.0 | 150.5 |
| សុខាភិបាល | 130.4 | 132.7 | 134.8 |
| ការដឹកជញ្ជូន | 110.3 | 111.6 | 116.1 |
| គមនាគមន៍ | 68.4 | 68.2 | 67.7 |
| ការកំសាន្ត និងវប្បធម៌ | 116.3 | 119.0 | 118.1 |
| ការសិក្សា | 160.0 | 160.1 | 159.4 |
| ភោជនីយដ្ឋាន | 238.5 | 248.6 | 266.0 |
| ទំនិញ និង សេវាកម្មផ្សេងៗ | 138.3 | 140.1 | 144.3 |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 2៖ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3 ៖ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៨*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |
| 2018 | 4,012 | 4,046 | 4,073 | |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

*រូបភាព 3 ៖ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៨*




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណូល*

| លានរៀល | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **I. ចំណូលក្នុងប្រទេស** | **3,414,261** | **3,922,552** | **4,669,879** |
| **១. ចំណូលចរន្ត** | **3,375,869** | **3,882,242** | **4,625,203** |
| ***ក. ចំណូលសារពើពន្ធ*** | **2,850,511** | **3,323,352** | **4,010,165** |
| **១. ពន្ធផ្ទាល់** | **577,746** | **727,351** | **803,728** |
| ពន្ធលើប្រាក់បៀវត្ស | 146,976 | 150,690 | 171,906 |
| ពន្ធលើប្រាក់ចំណេញ | 376,538 | 506,964 | 631,823 |
| ពន្ធលើផលទុនដីធ្លី និងផ្ទះសំបែង | 54,232 | 69,697 | 0 |
| **២. ពន្ធប្រយោល** | **1,800,755** | **2,120,269** | **2,621,198** |
| ពន្ធលើផលរបរ | 47 | **7** | **20** |
| អាករលើតម្លៃបន្ថែម | 1,054,061 | 1,207,285 | 1,419,699 |
| អាករពិសេស | 712,600 | 884,888 | 1,154,920 |
| ចំណូលពន្ធផ្សេងៗទៀត | 34,046 | 28,089 | 46,558 |
| **៣. ពន្ធពាណិជ្ជកម្មក្រៅប្រទេស** | **472,010** | **475,731** | **585,239** |
| ពន្ធនាំចូល | 463,310 | 462,590 | 572,700 |
| ពន្ធនាំចេញ | 8,550 | 12,968 | 12,385 |
| ពន្ធនាំចេញផ្សេងៗទៀត | 150 | 173 | 155 |
| ***ខ. ចំណូលមិនមែនសារពើពន្ធ*** | **525,358** | **558,891** | **615,038** |
| ចំណូលពីនេសាទ | 268 | 1,099 | 448 |
| ចំណូលពីព្រៃឈើ | 4,954 | 4,594 | 0 |
| ចំណូលពីការជួលសហគ្រាស | 1,955 | 3,450 | 1,000 |
| ចំណូលពីអាកាសចរស៊ីវិល | 30,873 | 33,161 | 53,063 |
| ចំណូលពីសម្បទាន | 50,557 | 88,702 | 116,043 |
| ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 14,812 | 18,038 | 23,789 |
| អាករស្មានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ) | 110,839 | 138,203 | 0 |
| ផលពីការបង់សិទ្ធិប្រលង | 18,872 | 38,598 | 0 |
| ចំណូលពីការជួល | 3,846 | 4,226 | 0 |
| ចំណូលមិនមែនពន្ធផ្សេងៗ | 288,382 | 228,820 | 420,695 |
| **២. ចំណូលមូលធន** | **38,392** | **40,310** | **44,676** |
| ការប្រមូលមកវិញនៃឥណទាន | 38,392 | 40,310 | 44,676 |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 5 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណាយ*

| លានរៀល | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **II. ចំណាយសរុប** | **4,088,466** | **4,809,223** | **5,570,520** |
| **១. ចំណាយចរន្ត** | **2,648,998** | **3,211,467** | **3,883,350** |
| ***ក. ការពារ និងសន្តិសុខជាតិ*** | **641,507** | **733,083** | **1,009,628** |
| ***ខ. រដ្ឋបាលស៊ីវិល*** | **1,857,555** | **2,345,820** | **2,714,838** |
| ***គ. ចំណាយការប្រាក់*** | **149,935** | **132,564** | **158,884** |
| **២. ចំណាយមូលធន** | **1,439,469** | **1,597,756** | **1,687,170** |
| ហិរញ្ញប្បទានក្នុងស្រុក | 514,046 | 428,648 | 1,310,862 |
| ពីចំណូលក្នុងស្រុក | 514,046 | 383,153 | 1,259,188 |
| ពីជំនួយជាទំនិញ | 0 | 45,495 | 51,674 |
| ហិរញ្ញប្បទានពីបរទេស | 925,422 | 1,169,108 | 376,309 |
| កែតម្រូវ | 2,717 | (26,108) | 0 |
| ***និទភាពចរន្ត (សាច់ប្រាក់)*** | **729,589** | **644,667** | **741,853** |
| ***និទភាពទូទៅ (សាច់ប្រាក់)*** | (671,488) | (912,779) | (900,641) |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 6 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកហិរញ្ញប្បទាន*

| លានរៀល | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **III. ហិរញ្ញប្បទាន** | **671,488** | **912,779** | **900,641** |
| **១. ហិរញ្ញប្បទានពីបរទេស** | **769,868** | **1,054,402** | **124,013** |
| ទ្រទ្រង់ថវិកា | 0 | 45,495 | 51,674 |
| ជំនួយគម្រោងអភិវឌ្ឍន៍ | 908,286 | 1,187,265 | 364,292 |
| រំលស់បំណុលបរទេស | (138,418) | (178,358) | (291,952) |
| **២. ហិរញ្ញប្បទានក្នុងស្រុក** | **66,622** | **66,160** | **(36,323)** |
| បញ្ញើរដ្ឋាភិបាល | 81,617 | (14,230) | (36,323) |
| វិស័យឯកជន | (19,541) | 80,390 | 0 |
| ផ្សេងៗ | 4,546 | 0 | 0 |
| **៣. ប្រតិបត្តិការកំពុងដំណើរការ** | **(165,002)** | **(207,783)** | **812,951** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 7÷ ចំណាយចរន្តតាមក្រសួង

| លានរៀល | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **សរុបចំណាយជាប្រចាំ** | **2,648,998** | **3,218,685** | **3,883,128** |
| **១.រដ្ឋបាលទូទៅ** | **803,758** | **993,596** | **1,122,256** |
| ព្រះបរមរាជវាំង | 18,079 | 26,601 | 21,260 |
| រដ្ឋសភា | 36,071 | 19,924 | 87,378 |
| ព្រឹទ្ធសភា | 6,664 | 15,576 | 27,083 |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 1,813 | 2,774 | 2,552 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 82,518 | 195,337 | 94,674 |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 3,006 | 4,754 | 3,550 |
| ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 22,832 | 33,167 | 40,677 |
| ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | 7,232 | 9,250 | 12,356 |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 25,245 | 30,095 | 26,405 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 540,243 | 565,845 | 617,109 |
| ក្រសួងផែនការ | 15,195 | 17,095 | 31,599 |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 21,749 | 29,068 | 35,193 |
| គ.ជ.ប | 4,833 | 23,510 | 94,643 |
| អាជ្ញាធរសវនកម្មជាតិ | 2,266 | 2,570 | 4,189 |
| អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ | 6,855 | 7,974 | 9,506 |
| ក្រសួងមុខងារសាធារណៈ | 9,158 | 10,056 | 14,082 |
| **២.ការពារ និងសន្តិសុខ** | **661,185** | **757,171** | **1,009,628** |
| ក្រសួងការពារជាតិ | 433,494 | 467,565 | 597,852 |
| ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 208,013 | 265,518 | 377,264 |
| ក្រសួងយុត្តិធម៌ | 19,678 | 24,088 | 34,512 |
| **៣.រដ្ឋបាលសង្គមកិច្ច** | **911,284** | **1,125,831** | **1,403,553** |
| ក្រសួងព័ត៌មាន | 12,557 | 15,878 | 16,994 |
| ក្រសួងសុខាភិបាល | 155,145 | 197,166 | 292,510 |
| ក្រសួងអប់រំ យុវជន និងកីឡា | 481,124 | 572,352 | 684,548 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 14,621 | 41,692 | 56,024 |
| ក្រសួងបរិស្ថាន | 13,356 | 18,743 | 24,382 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 176,460 | 206,696 | 251,676 |
| ក្រសួងធម្មការ និងកិច្ចការសាសនា | 14,495 | 14,938 | 20,248 |
| ក្រសួងកិច្ចការនារី | 11,295 | 11,438 | 13,047 |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 32,231 | 46,928 | 44,125 |

| លានរៀល | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **៤.រដ្ឋបាលសេដ្ឋកិច្ច** | **265,235** | **324,966** | **326,103** |
| រដ្ឋ. ដ្ឋានអាកាសចរណ៍ស៊ីវិល | 11,237 | 13,026 | 15,842 |
| ក្រសួងរ៉ែ និងថាមពល | 5,508 | 7,365 | 10,008 |
| ក្រសួងពាណិជ្ជកម្ម | 18,572 | 26,644 | 30,199 |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 42,138 | 56,000 | 64,637 |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 23,662 | 22,929 | 33,555 |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 11,191 | 14,734 | 19,331 |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | 115,318 | 119,282 | 95,738 |
| ក្រសួងទេសចរណ៍ | 14,166 | 18,893 | 20,127 |
| ក្រសួងធនធានទឹក និងឧតុនិយម | 15,597 | 33,897 | 23,881 |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 7,847 | 12,197 | 12,786 |
| **ចំណាយផ្សេងៗ** | **7,536** | **17,122** | **21,588** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *រូបភាព 4 ÷ ស្ថានភាពតុល្យភាពថវិកាចរន្ត (គិតជាលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. ឥណទាន និងរូបិយវត្ថុ

*តារាង 8÷ ស្ថានភាពរូបិយវត្ថុ*

| (ប៊ីលានរៀល) | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **32,188** | **43,302** | **52,640** |
| ទ្រព្យសកម្មបរទេស | 46,945 | 60,434 | 69,608 |
| ទ្រព្យអកម្មបរទេស | (14,757) | (17,133) | (16,968) |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **24,939** | **26,440** | **31,894** |
| ឥណទានក្នុងស្រុក | 46,634 | 53,145 | 64,582 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (7,917) | (10,348) | (13,004) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 54,551 | 63,493 | 77,585 |
| **ទ្រព្យសកម្មផ្នែកផ្សេងៗ** | **(21,695)** | **(26,705)** | **(32,688)** |
| ប្រាក់បញ្ញើហាមឃាត់ | (1,241) | (1,510) | (1,928) |
| មូលធន និង ធនបំរុង | (18,385) | (21,918) | (25,560) |
| ផ្សេងៗ | (2,070) | (3,277) | (5,200) |
| **រូបិយវត្ថុទូទៅ (M2)** | **57,128** | **69,742** | **84,534** |
| រូបិយវត្ថុ (M1) | 7,461 | 8,925 | 10,137 |
| *រូបិយវត្ថុក្រៅធនាគារ* | 6,713 | 7,987 | 9,199 |
| *ប្រាក់បញ្ញើចរន្ត* | 748 | 938 | 939 |
| រូបិយវត្ថុផ្សេងៗ | 49,667 | 60,817 | 74,397 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | 2,036 | 2,554 | 3,231 |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | 47,631 | 58,263 | 71,166 |
| **ទុនបម្រុងរូបិយប័ណ្ណបរទេសសុទ្ធ (លានដុល្លារ)** | **6,040** | **8,361** | na |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*រូបភាព 5÷ បរិក្ខារសំណង់ ទោចក្រ-យានយន្ត និងវាយនភ័ណ្ឌនិងសម្លៀកបំពាក់ (គិតជាប៊ីលានរៀល)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 9÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| ថ្នាំពេទ្យ | 131 | 158 | 204 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 407 | 471 | 644 |
| ស្ករស និងប៊ីចេង | 29 | 50 | 36 |
| ប្រេងឆា និងអាហារផ្សេងៗ | 235 | 310 | 407 |
| សម្ភារសំណង់ | 660 | 659 | 1,075 |
| អេឡិចត្រូនិច | 10 | 10 | 122 |
| វាយនភ័ណ្ឌ | 3,727 | 4,030 | 5,035 |
| ទោចក្រ-យានយន្ត | 887 | 1,013 | 1,329 |
| គ្រឿងបន្លាស់យានយន្ត | 13 | 14 | 27 |
| បរិក្ខារត្រជាក់ | 54 | 73 | 82 |
| មាស | 74 | 140 | 710 |
| ប្រេងឥន្ធនៈ | 1,265 | 867 | 1,213 |
| ជីកសិកម្ម | 268 | 346 | 231 |
| ផ្សេងៗ | 4,764 | 6,499 | 6,695 |
| **សរុប** | **12,523** | **14,640** | **17,811** |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 6៖ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាប៊ីលានរៀល)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 7៖ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 10 ÷ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| សម្លៀកបំពាក់ | 8,047 | 8,305 | 9,777 |
| ស្បែកជើង | 780 | 842 | 1,101 |
| វាយនភ័ណ្ឌផ្សេងៗ | 177 | 197 | 817 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 0 | 335 | 167 |
| គ្រឿងបង្គុំរថយន្ត | 0 | 5 | 62 |
| កង់ | 0 | 319 | 363 |
| ឈើមូល | 0 | 14 | 149 |
| ឈើកែច្នៃ | 0 | 0 | 0 |
| ក្តារបន្ទះ | 0 | 0 | 20 |
| ផលិតផលផ្សេងៗពីឈើ | 47 | 121 | 6 |
| អង្ករ | 219 | 271 | 361 |
| ស្រូវ | 0 | 0 | 0 |
| កៅស៊ូ | 198 | 293 | 243 |
| ស្ករស | 0 | 49 | 111 |
| ផលិតផលជលផល | 1 | 0 | 0 |
| ផលិតផលកសិកម្មផ្សេងៗ | 20 | 51 | 164 |
| បារី | 19 | 16 | 23 |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 0 | 0 | 173 |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0 | 0 | 9 |
| មាស | 306 | 0 | 0 |
| ផលិតផលផ្សេងៗ | 2,243 | 1,857 | 1,918 |
| **នាំចេញសរុប** | **12,057** | **12,674** | **15,466** |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៧. ការវិនិយោគឯកជន

*តារាង 11 ÷ ស្ថិតិវិនិយោគវិស័យឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **គម្រោង** | ចំនួន | 33 | 38 | 29 |
| **បង្កើតការងារ** | ការងារ | 32,577 | 46,374 | 54,809 |
| **ទុនវិនិយោគលើវិស័យ** | | | | |
| កសិកម្ម | លានដុល្លារ | 90 | 206 | 32 |
| ឧស្សាហកម្ម | លានដុល្លារ | 187 | 281 | 408 |
| សេវាកម្ម | លានដុល្លារ | 2 | 0 | 550 |
| ទេសចរណ៍ | លានដុល្លារ | 680 | 2,519 | 68 |
| **សរុប** | **លានដុល្លារ** | **959** | **3,005** | **1,059** |
| ទុនវិនិយោគក្នុងស្រុក | លានដុល្លារ | 36 | 2,550 | 769 |
| ទុនវិនិយោគបរទេស | លានដុល្លារ | 923 | 455 | 290 |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*រូបភាព 8 ÷ ចំនួនគម្រោង និងទុនវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស (គិតជាលានដុល្លារអាមេរិក)*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៨. វិស័យទេសចរណ៍

*តារាង 12 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា*

| សូចនាករ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ (*) |
| **សរុប** | **1,147,483** | **1,250,082** | **1,392,254** |
| តាមផ្លូវអាកាស | 602,150 | 777,745 | 971,468 |
| ភ្នំពេញ | 274,857 | 359,191 | 468,749 |
| សៀមរាប | 315,794 | 393,967 | 442,919 |
| កងកេង | 11,499 | 24,587 | 59,799 |
| តាមផ្លូវគោក និង ផ្លូវទឹក | 545,333 | 472,337 | 420,787 |
| ផ្លូវគោក | 516,587 | 453,593 | 401,424 |
| ផ្លូវទឹក | 28,746 | 18,744 | 19,362 |
| **តាមប្រភេទ** | **1,147,483** | **1,250,082** | **1,392,254** |
| អ្នកទេសចរ | 1,009,945 | 1,092,905 | 1,167,633 |
| អ្នកជំនួញ | 81,136 | 103,071 | 186,259 |
| ផ្សេងៗ | 56,402 | 54,106 | 38,361 |

ប្រភព: ក្រសួងទេសចរណ៍

(*) ធ្វើចំណោលទិន្នន័យខែកញ្ញា សម្រាប់ប៉ាន់ស្មានចំនួនភ្ញៀវក្នុងត្រីមាសទី៣។ ទិន្នន័យនេះ នឹងកែសម្រួលឡើងវិញក្នុងត្រីមាសទី៤

*រូបភាព 9 ÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 13 ៖ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 826 | 999 | 898 |
| ក្រឡាផ្ទៃ | ម$^{២}$ | **1,757,145** | **1,858,872** | **5,629,396** |
| តម្លៃសាងសង់ | លានដុល្លារ | 727 | 692 | 2,667 |
| **សំណើសុំសាងសង់តាមប្រភេទ** | | | | |
| សំណង់សាធារណៈ | ម$^{២}$ | 19,447 | 11,191 | 30,500 |
| លំនៅដ្ឋាន និងភូមិគ្រឹះ | ម$^{២}$ | 1,046,541 | 981,785 | 1,984,497 |
| សំណង់ឧស្សាហកម្ម | ម$^{២}$ | 384,342 | 436,468 | 447,920 |
| សំណង់ពាណិជ្ជកម្ម | ម$^{២}$ | 132,283 | 301,128 | 2,718,687 |
| សំណង់ទេសចរណ៍ | ម$^{២}$ | 171,440 | 128,179 | 447,223 |
| សំណង់វិនិយោគផ្សេងៗ | ម$^{២}$ | 3,092 | 120 | 568 |
| **សរុប** | **ម$^{២}$** | **1,757,145** | **1,858,872** | **5,629,396** |

ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព 10 ៖ សំណើសុំវិនិយោគសាងសង់ គិតជាក្រឡាផ្ទៃ ចែកតាមប្រភេទសំណង់*




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 14 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី៣ | | |
|---|---|---|---|---|---|
| | | | ២០១៦ | ២០១៧ | ២០១៨ |
| អង្ករ | តោន/ដុល្លារ | បាងកក | 415 | 376 | 405 |
| ប្រេងឆៅ Brent | ធុង/ដុល្លារ | ក្រុងឡុង | 46 | 51 | 73 |
| កៅស៊ូ | តោន/ដុល្លារ | សឹង្ហបុរី | 1,552 | 1,837 | 1,474 |
| មាស | អោន/ដុល្លារ | ហុងកុង | 1,470 | 1,408 | 1,318 |
| ពោតក្រហម | តោន/ដុល្លារ | ស៊ីកាហ្គោ | 151 | 148 | 162 |
| សណ្តែកសៀង | តោន/ដុល្លារ | ស៊ីកាហ្គោ | 414 | 390 | 407 |
| ប្រេងដូង | តោន/ដុល្លារ | រ៉ុតធើឌាំ | 1,537 | 1,604 | 903 |
| ស្ករស | តោន/ដុល្លារ | ក្រុងឡុង | 366 | 386 | 377 |

ប្រភព: គេហទំព័រធនាគារពិភពលោក

*រូបភាព 11 ÷ ថ្លៃជីកសិកម្មលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក/ម៉ែត្រទ្រីកតោន)*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 15 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| ប្រេងឥន្ធនៈ | 45 | 50 | 71 |
| ផលិតផលកសិកម្ម | 91 | 86 | 85 |
| ម្ហូបអាហារ | 95 | 89 | 89 |
| ឈើ | 89 | 86 | 86 |
| ជីគីមី | 71 | 69 | 85 |

ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*រូបភាព 12 ÷ សន្ទស្សន៍ថ្លៃមុខទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 16 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី៣ | | |
|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៨ |
| ជប៉ុន (យ៉េន) | 101.29 | 112.53 | 113.68 |
| ហុងកុង (ដុល្លារ) | 7.75 | 7.81 | 7.83 |
| សឹង្ហបុរី (ដុល្លារ) | 1.36 | 1.36 | 1.37 |
| ម៉ាឡេស៊ី (រីងហ្គីត) | 4.12 | 4.22 | 4.14 |
| ហ្វីលីពីន (ប៉េសូ) | 48.25 | 50.83 | 53.88 |
| ថៃ (បាត) | 34.58 | 33.28 | 32.18 |
| ឥណ្ឌូនេស៊ី (រូព្យា) | 12,970.20 | 13,442.20 | 14,899.00 |
| កូរ៉េ (វ៉ូន) | 1,096.97 | 1,144.61 | 1,109.32 |
| តៃវ៉ាន់ (ដុល្លារ) | 31.37 | 30.34 | 30.45 |
| ចិន (រ៉េនមីនប៊ី) | 6.67 | 6.66 | 6.87 |
| ឡាវ (គីប) | 4,026.35 | 3,996.48 | 4,072.50 |
| វៀតណាម (ដុង) | 7,951.69 | 8,169.40 | 8,502.50 |
| ឥណ្ឌា (រូពី) | 22,096.60 | 22,477.50 | 23,318.50 |
| រុស្សី (រូប) | 66.59 | 65.42 | 72.33 |
| អូស្ត្រាលី (ដុល្លារ) | 63.09 | 57.73 | 65.56 |
| អង់គ្លេស (ផោន) | 1.30 | 1.28 | 1.38 |
| អឺរ៉ុប (អឺរ៉ូ) | 0.77 | 0.75 | 0.77 |

ប្រភព: OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 17÷ ស្ថិតិកសិកម្ម*

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី៣ | | |
|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ |
| ផ្ទៃដីដាំដុះ | | | | |
| ស្រូវ | ហិកតា | 2,518,874 | 2,609,617 | 2,728,274 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 900,442 | 869,383 | 923,838 |
| កៅស៊ូ | ហិកតា | 402,310 | 432,096 | 427,000 |
| ផ្ទៃដីប្រមូលផល | | | | |
| ស្រូវ | ហិកតា | 190,272 | 348,619 | 429,972 |
| កៅស៊ូ | ហិកតា | 123,271 | 163,132 | 201,000 |
| បរិមាណផល | | | | |
| ស្រូវ | តោន | 767,149 | 1,391,545 | 1,715,753 |
| កៅស៊ូ (ក្រែប) | តោន | 85,641 | 123,643 | na |
| ជលផល | តោន | 507,400 | 527,483 | 567,668 |
| នាំចេញ | | | 801,824 | 1,083,889 |
| អង្ករ | តោន | 352,916 | 384,632 | 396,055 |
| ស្រូវ | តោន | - | 2,485 | - |
| កៅស៊ូ | តោន | 87,254 | 109,614 | 108,166 |
| ស្ករ | តោន | - | 111,799 | 296,500 |
| ផលិតផលជលផល | តោន | 123 | 203 | 1,760 |
| ផលិតផលកសិកម្មផ្សេងៗ | តោន | 83,847 | 193,091 | 281,408 |

ប្រភព៖ របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
របាយការណ៍ពាណិជ្ជកម្មប្រចាំខែ

*រៀបចំដោយនាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ*

*ទំនាក់ទំនង៖ (855) 12 997 616*

*(855) 89 898 878*

*Email: sead@mef.gov.kh*